**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ០៩៨០ ព.ណ.ភព..

ថ្ងៃសុក្រ ៤កើត ខែជេស្ឋ ឆ្នាំមមីសប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៦

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ លោក-លោកស្រី ជាធុរជន សហគ្រិន វិនិយោគិន និងសាធារណជនទូទៅឱ្យបានជ្រាបថា ក្រសួងពាណិជ្ជកម្មនៃសាធារណរដ្ឋប្រជាមានិតចិន នឹងរៀបចំ **«ពិព័រណ៍ពាណិជ្ជកម្មទំនិញនាំចូលអន្តរជាតិចិន លើកទី៩- The 9th China International Import Expo (CIIE)»** ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី៥-១០ ខែវិច្ឆិកា ឆ្នាំ២០២៦ នៅទីក្រុងសៀងហៃ សាធារណរដ្ឋប្រជាមានិតចិន។

**«ពិព័រណ៍ពាណិជ្ជកម្មទំនិញនាំចូលអន្តរជាតិចិន»** គឺជាព្រឹត្តិការណ៍ពាណិជ្ជកម្មដ៏ធំមួយរបស់ប្រទេសចិន និងជាវេទិកាធុរកិច្ចដ៏សំខាន់សម្រាប់កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មអន្តរជាតិ ការវិនិយោគ និងការទំនាក់ទំនងដៃគូពាណិជ្ជកម្មរវាងបណ្តាប្រទេសចូលរួមទាំងអស់ ជាមួយប្រទេសចិន។ ព្រឹត្តិការណ៍ពិព័រណ៍នេះក៏នឹងមានការរៀបចំសាងសង់ពន្លាជាតិ (Country Pavilion) របស់ប្រទេសចូលរួមនីមួយៗ ដែលក្នុងនោះក្រសួងពាណិជ្ជកម្មក៏នឹងបន្តរៀបចំសាងសង់ពន្លាជាតិកម្ពុជាផងដែរ។ បន្ថែមលើនេះ ពិព័រណ៍នេះ ក៏នឹងមានស្តង់ពិព័រណ៍ពាណិជ្ជកម្មដ៏សម្បូរបែប ដែលនឹងដាក់តាំងបង្ហាញផលិតផលរួមមាន៖ បរិក្ខារពេទ្យ ផលិតផលថែទាំសុខភាព រថយន្ត ឧបករណ៍បច្ចេកទេស ទំនិញប្រើប្រាស់ទូទៅ ផលិតផលកសិកម្ម ពាណិជ្ជកម្ម សេវាកម្ម និងផលិតផលនវានុវត្តន៍ជាដើម ព្រមទាំងមានរៀបចំវេទិកាពាណិជ្ជកម្មអមជាច្រើន។

ក្រសួងពាណិជ្ជកម្ម ក្នុងនាមអ្នកសម្របសម្រួលព្រឹត្តិការណ៍ពិព័រណ៍ខាងលើ សូមអញ្ជើញ លោក-លោកស្រី ដែលជាធុរជន សហគ្រិន វិនិយោគិន និងសាធារណជន ដែលមានចំណាប់អារម្មណ៍ចង់ចូលរួមដាក់តាំងបង្ហាញផលិតផល/សេវាកម្ម ក្នុងព្រឹត្តិការណ៍ពិព័រណ៍ខាងលើ សូមទំនាក់ទំនងមកមន្ត្រីសម្របសម្រួលតាមរយៈទូរស័ព្ទលេខ +៨៥៥ ១៦ ៤១៦ ៨២៥ ឬតាមរយៈប្រព័ន្ធទូរស័ព្ទសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ១២៦៦ ឬអ៊ីម៉ែល chao.katphuoy@moc.gov.kh ឬបំពេញបែបបទចូលរួមតាមរយៈ QR Code ខាងក្រោម៕

**សូមអរគុណ!**

សម្រាប់ចុះឈ្មោះ

GO.gov.kh

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469